Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 1

# អធិដ្ឋានតាមមាលា

អ្នកអធិដ្ឋានតាមមាលារួមចិត្តគំនិត ជាមួយនាងម៉ារីដែលជាគ្រីស្តបរិស័ទដើមដំបូងនិងជាគ្រីស្តបរិស័ទគំរូ នឹកសញ្ជឹងអំពីព្រឹត្តិការណ៍សំខាន់ៗនៃការសង្គ្រោះ ។

តាមប្រពៃណីព្រះសហគមន៍ត្រូវសូត្រធម៌«ឱព្រះបិតា» ១ ដង រួចធម៌ «បពិត្រព្រះនាងម៉ារី» ១០ ដង និងធម៌ «សូមកោតសរសើរ» ១ ដង ។

ពេលសូត្រធម៌«បពិត្រព្រះនាងម៉ារី»ត្រូវនឹកសញ្ជឹងអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យមួយក្នុងចំណោមព្រឹត្តិការណ៍ទាំង ៤ ដែលព្រះជាម្ចាស់បានប្រព្រឹត្ត ដើម្បីសង្គ្រោះមនុស្សលោក ។

ព្រឹត្តិការណ៍ដ៏អស្ចារ្យទាំង៤ ដែលគ្រីស្តបរិស័ទធ្លាប់អធិដ្ឋានតាមថ្ងៃមានដូចខាងក្រោមនេះ គឺ៖

១- ព្រឹត្តិការណ៍នាំឲ្យអរសប្បាយ (ថ្ងៃច័ន្ទ)
២- ព្រឹត្តិការណ៍សម្តែងព្រះពន្លឺ (ថ្ងៃព្រហស្បតិ៍)
៣- ព្រឹត្តិការណ៍នៃទុក្ខលំបាក (ថ្ងៃអង្គារ និងសុក្រ)
៤- ព្រឹត្តិការណ៍សម្តែងសិរីរុងរឿង (ថ្ងៃពុធ និងសៅរ៍)

ព្រឹត្តិការណ៍នីមួយៗមាន ៥ ភាគ ។

---

▶▶ ឃ្លារិះគិត

● ពាក្យសូមអង្វរ ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 2

# របៀបអធិដ្ឋានតាម
# មាលា



Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 3



Prieres Rosaire corigee  Mai.2011:Rosaire-livre.qxp  6/9/2011  11:05 AM  Page 4





## ធម៌ "បពិត្រព្រះនាងម៉ារី"

បពិត្រព្រះនាងម៉ារីជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមព្រះនាងមានអំណរសប្បាយ ព្រះអង្គគង់ជាមួយនាង
ព្រះអង្គបានប្រទានពរដល់នាងលើសស្ត្រីទាំងឡាយ
ហើយទ្រង់ក៏ប្រទានពរដល់បុត្រព្រះនាងដែរ ។
ឱ! សន្តីម៉ារី ជាមាតាព្រះអម្ចាស់!
សូមជួយអង្វរព្រះអង្គឲ្យយើងខ្ញុំជាអ្នកបាប
នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង ។ អាម៉ែន ។

## ធម៌ "សូមកោតសរសើរ"

សូមកោតសរសើរព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលព្រះអង្គគង់នៅតាំងពីដើមរៀងមក
ហើយជាដរាបតរៀងទៅ ។
អាម៉ែន ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 5

# ព្រឹត្តិការណ៍នាំឱ្យអរសប្បាយ



Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 6

# ១. ព្រះជាម្ចាស់ចាត់ទេវទូតមកជូនដំណឹងព្រះនាងម៉ារី

**« នាងនឹងមានគភ៌ សម្រាលបានបុត្រមួយ**
**ដែលនាងត្រូវថ្វាយព្រះនាមថា យេស៊ូ »** (លក ១,៣១)



▸▸ *ព្រះយេស៊ូមានសម្បត្តិដ៏ច្រើន*
*ព្រះអង្គបានដាក់ខ្លួនមកជាអ្នកក្រីក្រព្រោះតែបងប្អូន ។* (២ ករ ៨,៩)

● សូមព្រះបិតាជាអម្ចាស់
ប្រោសប្រណីដល់យើងខ្ញុំទាំងអស់គ្នានៅទីនេះ និង
អស់អ្នកឯទៀតៗដែលទទួលទាំងដំណឹងល្អ និងដំណឹងអាក្រក់ដែរ ។

# ២. ព្រះនាងម៉ារីទៅជម្រាបសួរនាងអេលីសាបិត

**ពេលនាងអេលីសាបិតឮព្រះនាងម៉ារី**
**ជម្រាបសួរ ទារកក្នុងផ្ទៃនាងក៏បំរះឡើង។** (លក ១,៤១)



*នាងអេលីសាបិតបន្លឺសម្លេងថា៖*
*«នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿ» ។* (លក ១,៤៥)

● សូមព្រះបិតាជាអម្ចាស់
ប្រោសឲ្យយើងខ្ញុំរួមជាមួយអស់អ្នក
ដែលយកចិត្តទុកដាក់បម្រើអ្នកដទៃផង ។

# ៣. ព្រះយេស៊ូប្រសូតមកក្នុងលោកយើងនេះ

**ព្រះនាងម៉ារី សម្រាលបុត្រមួយ ជាបុត្រច្បង។**
**ព្រះនាងរុំបុត្រនោះនឹងសំពត់ រួចដាក់ឲ្យផ្ទំក្នុងស្នូក។** (លក ២,៧)



▸▸ *ព្រះអម្ចាស់បានទៅជាមនុស្សដូចមនុស្សឯទៀត ហើយក៏រស់នៅក្នុងភាពជាមនុស្សសាមញ្ញដែរ ។* (ភល ២,៧)

● សូមព្រះបិតាជាអម្ចាស់ ប្រោសឲ្យយើងខ្ញុំ រួបរួមជាមួយអស់អ្នកដែលយកចិត្តទុកដាក់ការពារជីវិតផង ។



# ៤. ព្រះនាងម៉ារីបីព្រះឱរសយេស៊ូ ទៅថ្វាយព្រះជាម្ចាស់

**ភ្នែកទូលបង្គំបានឃើញការសង្គ្រោះ**
**ដែលព្រះអង្គបានប្រទានមកឲ្យប្រជាជាតិទាំងអស់។** (លក ២,៣០-៣១)



▸▸ *នៅពេលព្រះគ្រីស្តយាងចូលក្នុងពិភពលោក*
*ព្រះអង្គមានព្រះបន្ទូលថា៖ «បពិត្រព្រះជាម្ចាស់ ឥឡូវនេះ*
*ទូលបង្គំសូមមកធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ» ។* (ហប ១០,៧)

● បពិត្រព្រះបិតាជាអម្ចាស់
សូមព្រះអង្គប្រោសឲ្យប្រជាជាតិនានារកឃើញពន្លឺរបស់ព្រះគ្រីស្តផង ។





# ៥. នាងម៉ារីនិងលោកយ៉ូសែប រកឃើញព្រះកុមារយេស៊ូ ក្នុងព្រះវិហារ

**ព្រះកុមារមានព្រះបន្ទូលតបថា៖**
**« កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូន » ។** (លក ២,៤៩)



*« ព្រះបិតាគង់នៅជាមួយខ្ញុំ ខ្ញុំតែងប្រព្រឹត្ត កិច្ចការណាដែលគាប់ព្រះហឫទ័យព្រះអង្គជានិច្ច»* (យហ ៨,២៩)

● បពិត្រព្រះបិតាជាអម្ចាស់
សូមព្រះអង្គប្រោសឲ្យយើងខ្ញុំរួមជាមួយអស់អ្នកទាំងឡាយ
ដែលកំពុងជម្រាបបន្តជំនឿរបស់គ្រីស្តបរិស័ទដល់អ្នកឯទៀតផង ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 11

# ព្រឹត្តិការណ៏សម្តែងព្រះពន្លឺ



## ១. ព្រះយេស៊ូទទួលពិធីជ្រមុជទឹក

**ពេលព្រះយេស៊ូយាងឡើងពីទឹកមកភ្លាម**
**ទ្រង់ទតឃើញផ្ទៃមេឃរហែកជាពីរ ហើយព្រះវិញ្ញាណ**
**យាងចុះ ដូចសត្វព្រាប មកសណ្ឋិតលើព្រះអង្គ។** (មក ១,១០)



*▸▸ យើងបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណ*
*តែមួយ ដើម្បីផ្សំគ្នាឡើងជាព្រះកាយតែមួយ ។* (១ករ ១២,១៣)

● បពិត្រព្រះបិតាជាអម្ចាស់
សូមព្រះអង្គប្រោសអស់អ្នកដែលមានបន្ទុក
ដឹកនាំប្រជាជាតិនានា សូមឲ្យគេបណ្ដោយខ្លួនឲ្យព្រះវិញ្ញាណណែនាំ ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 13



# ២. *ព្រះយេស៊ូវប្រែទឹកឱ្យក្លាយជាស្រា*

**ការអស្ចារ្យនេះ**
**ជាទីសម្គាល់ដំបូងបង្អស់ដែលព្រះយេស៊ូបានធ្វើ។ ព្រះអង្គ**
**បានសម្ដែងសិរីរុងរឿង ហើយពួកសាវ័កក៏ជឿលើព្រះអង្គ។**(យហ ២,១១)



*ព្រះយេស៊ូបានធ្វើទីសម្គាល់ផ្សេងៗជាច្រើនទៀត ដើម្បីឲ្យ អ្នកជឿមានជីវិតដោយរួមជាមួយព្រះអង្គ ។* (យហ ២០,៣០-៣១)

● បពិត្រព្រះបិតាជាអម្ចាស់
សូមព្រះអង្គប្រោសឲ្យគូស្រករទាំងអស់ ស៊ូទ្រាំ
រស់នៅជាមួយគ្នា ទោះបីគេជួបការលំបាកយ៉ាងណាក្ដី ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 14

# ៣. ព្រះយេស៊ូប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់

**« ចូរកែប្រែចិត្តគំនិត**
**ដ្បិតព្រះរាជ្យនៃស្ថានបរមសុខនៅជិតបង្កើយហើយ! »** (មថ ៤,១៧)



▸▸ *ព្រះអង្គប្រោសអ្នកជំងឺផ្សេងៗជាច្រើន ឲ្យបានជាសះស្បើយ ។*

(លក ៤,៤០)

● សូមព្រះបិតាជាអម្ចាស់ មេត្តាបង្ហាញព្រះភ័ក្ត្រព្រះអង្គ ដល់អស់បងប្អូនដែលសង្គមបោះបង់ចោល ជាពិសេសស្ត្រីពេស្យា អ្នកស្រឡាញ់ភេទដូចគ្នា អស់អ្នកដែលរស់ដោយសារគំនិតសម្រាមជាដើមផង ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 15



# ៤. ព្រះជាម្ចាស់បង្ហាញសិរីរុងរឿងរបស់ព្រះយេស៊ូ

**ព្រះភ័ក្ត្ររបស់ព្រះយេស៊ូ**
**បញ្ចេញរស្មីចែងចាំងដូចពន្លឺថ្ងៃ ហើយព្រះពស្ត្រ**
**របស់ព្រះអង្គ ត្រឡប់ជាមានពណ៌សដូចពន្លឺ។** (មថ ១៧,២)



*ព្រះអង្គនឹងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់យើងនេះឲ្យ បានដូចព្រះកាយប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ ។* (ភល ៣,២១)

● សូមព្រះបិតាជាអម្ចាស់ មេត្តាបង្ហាញរស្មីពណ្ណរាយរបស់ព្រះអង្គ ដល់អស់អ្នកដែលមានស្នាមរបួសលើមុខលើរាងកាយ រួមជាមួយជនពិការ និងអ្នកដែលយើងខ្ញុំមិនស្រឡាញ់គេផង ។

# ៥. ព្រះយេស៊ូបូជាព្រះជន្មសម្រាប់មនុស្សលោក

**« នេះជារូបកាយ និងលោហិតរបស់ខ្ញុំ**
**ដែលចងសម្ពន្ធមេត្រីថ្មី សម្រាប់អ្នករាល់គ្នា »** (មក ១៤,២២-២៤)



▸▸ *ព្រះជាម្ចាស់បានលោះយើងដោយព្រះលោហិតរបស់ព្រះគ្រីស្ត ។*

(អភ ១,៧)

● សូមព្រះបិតាជាអម្ចាស់!
មេត្តាប្រោសឲ្យយើងខ្ញុំសុខចិត្តបូជាជីវិតរួមជាមួយ
ព្រះបុត្រាដែលបូជាព្រះជន្មដោយព្រះហឫទ័យស្រឡាញ់ផង ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 17

# ព្រឹត្តិការណ៍នៃទុក្ខលំបាក



Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 18

# ១. ព្រះយេស៊ូស្លុតរន្ធត់នៅក្នុងសួនច្បារកេតសេម៉ានី

**ព្រះយេស៊ូទូលថា៖ « អ័ប្បា ឱព្រះបិតាអើយ!**
**សូមឲ្យបានសម្រេចតាមព្រះហឫទ័យព្រះអង្គវិញ » ។** (មក ១៤,៣៣-៣៦)



*ព្រះគ្រីស្តគ្មានបាបទាល់តែសោះ*
*ព្រះអង្គទៅជាតួបាបសម្រាប់យើង ដើម្បីប្រោសយើង*
*ឲ្យបានសុចរិត រួមជាមួយព្រះគ្រីស្តដែរ ។* (២ករ ៦,២១)

- សូមព្រះបិតាជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រោសដល់អស់អ្នក
ដែលបានសម្រេចចិត្តជ្រើសរើសធ្វើកិច្ចការដ៏សំខាន់ៗក្នុងថ្ងៃនេះផង ។

# ២. ព្រះយេស៊ូត្រូវគេវាយនឹងរំពាត់

**ពេលនោះ  លោកពីឡាត**
**បង្គាប់ឲ្យទាហានយកព្រះយេស៊ូ ទៅវាយនឹងរំពាត់។** (យហ ១៩,១)



*លោកទទួលការឈឺចាប់ពេញក្នុងខ្លួន ។*
*យើងក៏បានជាសះស្បើយដោយសារស្នាមរបួសរបស់លោក ។*

(អស  ៥៣,៣-៥)

● សូមព្រះបិតាជាអម្ចាស់ ប្រោសប្រណីឲ្យយើងខ្ញុំចូលរួមជាមួយអស់អ្នកដែលឈឺចុកចាប់ខាងរាងកាយ និងអស់អ្នកដែលត្រូវគេធ្វើបាបផង ។

# ៣. គេបំពាក់មកុដបន្លាលើព្រះយេស៊ូ

**ពួកទាហានគោរពព្រះយេស៊ូ**
**ទាំងពោលចំអកថា៖ « សូមគោរពថ្វាយបង្គំស្ដេចយូដា! » ។**(មក ១៥,១៦)



▸▸ *លោកត្រូវរបួសព្រោះបាបកម្មរបស់យើង លោកត្រូវគេជាន់ញក់ញី ព្រោះតែអំពើអាក្រក់របស់យើង ។*(អស ៥៣,៥)

● សូមព្រះបិតាជាអម្ចាស់
មេត្តាប្រោសប្រណីដល់អស់អ្នកដែល
ត្រូវគេចំអកឡកឡឺយ និងអ្នកត្រូវគេមើលងាយផង ។

# ៤. ព្រះយេស៊ូលីឈើឆ្កាង

**ព្រះយេស៊ូលីឈើឆ្កាង**
**ដោយផ្ទាល់ព្រះអង្គ ឆ្ពោះទៅ« ទួលលលាដ៍ក្បាល » ។** (យហ ១៩,១៧)



▸▸ *«អ្នកណាចង់តាមខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ»* (លក ៩,២៣)

● សូមព្រះបិតាជាអម្ចាស់
ប្រោសប្រណីឲ្យយើងខ្ញុំចូលរួមជាមួយ
អស់អ្នកដែលកំពុងលីឈើឆ្កាងដើរតាមព្រះអង្គផង ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 22

# *៥. ព្រះយេស៊ូសោយទិវង្គត*

ព្រះយេស៊ូបន្លឺព្រះសូរសៀង
ខ្លាំងៗថា៖ « ព្រះបិតា! ទូលបង្គំសូមប្រគល់
វិញ្ញាណរបស់ទូលបង្គំ ទៅក្នុងព្រះហស្តព្រះអង្គវិញ » ។ (លក ២៣, ៤៦)



▸▸ *ខ្ញុំរស់ដោយមានជំនឿទៅលើព្រះបុត្រា*
*ដែលបានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសម្រាប់ខ្ញុំ ។* (កាឡ ២, ២០)

● សូមព្រះបិតាជាអម្ចាស់
មេត្តាប្រោសប្រទានកម្លាំងចិត្តដល់អស់អ្នក
ដែលហៀបនឹងទទួលមរណភាព ទាំងគ្មានចិត្តសង្ឃឹមផង ។

# ព្រឹត្តិការណ៍សម្តែងសិរីរុងរឿង



# ១. ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

**ទេវទូតនិយាយទៅកាន់ស្ត្រីៗថា៖**
**« កុំភ័យខ្លាចអ្វី! ព្រះយេស៊ូមិននៅទីនេះទេ ព្រះអង្គមានព្រះជន្មរស់ឡើងវិញដូចទ្រង់មានព្រះបន្ទូលរួចមកហើយ »។** (មថ ២៨,៥-៦)



*ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ ។* (រ៉ូម ៦,៨-៩)

● សូមព្រះបិតាជាអម្ចាស់
មេត្តាប្រោសប្រណី ឲ្យយើងខ្ញុំចូលរួមជាមួយ
អស់អ្នកដែលបានឆ្លងកាត់គ្រាដ៏លំបាកទាំងឡាយផង ។



# ២. ព្រះយេស៊ូយាងឡើងស្ថានបរមសុខ

**នៅពេលដែលព្រះយេស៊ូ**
**កំពុងតែប្រទានពរដល់ក្រុមសាវ័ក ព្រះជាម្ចាស់**
**លើកយកព្រះអង្គចេញពីគេ ឡើងទៅស្ថានបរមសុខ។** (លក ២៤,៥១)



*«ខ្ញុំទៅរៀបចំកន្លែងដែលខ្ញុំនៅទុកសម្រាប់អ្នករាល់គ្នា»*

(យហ ១៤,២)

● សូមព្រះបិតាជាអម្ចាស់
មេត្តាប្រោសប្រទាន ឲ្យយើងខ្ញុំចូលរួមជាមួយ
អស់អ្នកដែលតស៊ូដើម្បីស្វែងរកតម្លៃនៃជីវិតផង ។

# ៣. ព្រះវិញ្ញាណយាងមកសណ្ឋិតលើក្រុមសាវ័ក

**អ្នកទាំងនោះបានពោរពេញ
ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្ដើមនិយាយ
ភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានឲ្យ។** (កក ២,៤)



*▸▸ រូបកាយរបស់បងប្អូនជាព្រះវិហារ
របស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់នៅក្នុងបងប្អូន ។* (១ករ ៦,១៩)

● សូមព្រះបិតាជាអម្ចាស់
ប្រោសឲ្យយើងខ្ញុំរួមជាមួយគ្រីស្តបរិស័ទទាំងអស់
ដែលជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធផង ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 27



# ៤. ព្រះជាម្ចាស់លើកនាងម៉ារីឡើងស្ថានបរមសុខ

**អស់អ្នកដែល**
**ព្រះជាម្ចាស់បានត្រាស់ហៅ**
**ទ្រង់ក៏ប្រទានឲ្យគេមានសិរីរុងរឿងដែរ។** (រ៉ូម ៨,៣០)



*«ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង*
*ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ»* (លក ១,៤៧)

● យើងសូមអង្វរព្រះបិតា
រួមជាមួយស្ត្រីទាំងអស់ក្នុងពិភពលោកទាំងមូល សូមឲ្យស្ត្រីមានចិត្តក្លាហាន បំពេញការងារ តួនាទី និងបេសកកម្មរបស់ខ្លួន ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 28

# ៥. ព្រះជាម្ចាស់ប្រទានសិរីរុងរឿងឱ្យនាងម៉ារី

**ព្រះជាម្ចាស់**
**បានប្រោសយើងឲ្យរស់ឡើង និងអង្គុយលើបល្ល័ង្ក**
**នៅស្ថានបរមសុខ រួមជាមួយព្រះយេស៊ូគ្រីស្តដែរ។** (អភ ២,៦)



*នាងម៉ារីថ្លែងថា៖*
*«អំណើះតទៅ មនុស្សគ្រប់ជំនាន់នឹងពោលថា*
*ខ្ញុំជាអ្នកមានសុភមង្គលពិតមែន» ។* (លក ១,៤៨)

● សូមព្រះបិតាជាអម្ចាស់ ប្រោសប្រទានពរដល់ប្រទេស
ទាំងឡាយ ដែលមិនទាន់មានសន្តិភាពនៅឡើយជង ជាពិសេស ... ។

# ធម៌ "ប្រកាសជំនឿ"

- ខ្ញុំជឿលើព្រះបិតា ដ៏មានតេជានុភាពសព្វប្រការ ជាព្រះបង្កើតមេឃ និងដី ។

- ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់យើងខ្ញុំ ។

ព្រះអង្គចាប់កំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ព្រះអង្គបានសោយទុក្ខលំបាក នៅជំនាន់លោកប៉ុនពីឡាត ។ ព្រះអង្គត្រូវគេឆ្កាង សោយព្រះទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ ។

ព្រះអង្គបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទីបី ទ្រង់មានព្រះជន្មរស់ឡើងវិញ រួចព្រះអង្គបានយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្តាំព្រះបិតា ដ៏មានតេជានុភាពសព្វប្រការ ។ ព្រះអង្គនឹងយាងមកវិញ ដើម្បីកាត់ក្តីបាបកុសល ឲ្យមនុស្សទាំងរស់ ទាំងស្លាប់ ។

- ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំជឿលើព្រះសហគមន៍កាតូលិកនិងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ខ្ញុំជឿថា មានការលើកលែងទោសរំដោះបាប ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ ព្រមទាំងមានជីវិតរស់នៅ អស់កល្បជានិច្ចផង ។

អាម៉ែន ។

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 30



លោកអភិបាលព្រះសហគមន៍កាតូលិកភ្នំពេញ

**អេមីល ដេតម្ប**

អនុញ្ញាតឲ្យបោះពុម្ពផ្សាយ

(បោះពុម្ពលើកទី ២)

មណ្ឌលអប់រំជំនឿកាតូលិកកម្ពុជា (CCCC)

ទូរស័ព្ទលេខ (855 23) 211 253, E mail: 4c@online.com.kh

Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 31



Prieres Rosaire corigee Mai.2011:Rosaire-livre.qxp 6/9/2011 11:05 AM Page 32

## អធិដ្ឋាន

### ធម៌ “ឱ ព្រះបិតា”

*ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ!*
*សូមសម្តែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ*
*សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់*
*សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី*
*ដូចនៅស្ថានបរមសុខដែរ ។*

- *សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ ។*
- *សូមអត់ទោសឲ្យយើងខ្ញុំ*
- *ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក*
  *ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ ។*
- *សូមកុំបណ្តោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ ។*
- *តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាច ។*

*អាម៉ែន ។*